# ក្ដីសង្ឃឹមឃាតករ ?

ជនខ្មែរមួយក្រុម នាំគ្នាផ្សាយគំនិតថា វាមានការប្រេះឆានៅក្នុងគណបក្សប្រជាជន ដែលមាន ស ខេង ជាមេខ្លោងប្រឆាំងនឹង ហ៊ុន សែន។ គំនិតនេះ វាជាឧបាយកល នៃគំនិត ដើម្បីបញ្ឆោតគូប្រជែង ហ៊ុន សែន ឱ្យមានក្ដីសង្ឃឹមថា សម រង្ស៊ី នឹងចាប់យករបារនេះ សំរាប់លោតចូលស្រុកខ្មែរ ដោយងាយស្រួល។ សម រង្ស៊ី ខ្លួនឯង ក៏គាត់ធ្លាក់ចូលក្នុងអន្ទាក់នេះ ហើយគាត់បង្ហាញក្ដីសង្ឃឹមរបស់គាត់ ចំពោះសាធារណ:ជនថា គាត់គឺជាមនុស្សម្នាក់ ដែលកោតសរសើរសព ជា ស៊ីម ដែលជាអតីតប្រធានគណបក្សប្រជាជន និង ជាបិតា នៃគំនិតនយោបាយរបស់ ស ខេង, ដ្បិតនរ:ជននេះ តែងតែមានគំនិតផ្សះផ្សាជាតិដើម្បីសន្តិភាព នៃប្រជាជាតិខ្មែរ។ តែ សម រង្ស៊ី មិនបានយកសកម្មភាពនយោបាយ ជា ស៊ីម តាំងពី ឆ្នាំ ១៩៧០ រហូតដល់ស្លាប់ មកពិនិត្យ ដែលសុទ្ធជាសកម្មភាពកុម្មុយនិស្ត ប្រឆាំងនឹងពុទ្ធសាសនា និង ប្រជាជាតិខ្មែរ រហូតស្ម័គ្រចូលបំរើពួកយួនកុម្មុយនិស្ត ដើម្បីកសាងឥណ្ឌូចិនយៀកណាម។ ជា ស៊ីម ក្នុងឋាន:ជា ប្រធានគណបក្សប្រជាជន គាត់បានចូលរួមយ៉ាងសកម្ម ដើម្បីបំផ្លាញកិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ ដូចយ៉ាង បដិសេធ មិនព្រមទទួលយកលទ្ធផលបោះឆ្នោតនៅ ឆ្នាំ ១៩៩៣, រដ្ឋប្រហារយោធានៅឆ្នាំ ១៩៩៧, សន្ធិសញ្ញាបន្ថែម ខ្មែរ-យៀកណាម នៅឆ្នាំ ២០០៥ ដែលនាំធ្វើឱ្យ

## ក្ដីសង្ឃឹមឃាតករ

សន្ធិសញ្ញា នៅឆ្នាំ ១៩៧៩, ១៩៨២, ១៩៨៣ និង ១៩៨៥ ដែលធ្វើឡើង នៅក្រោមការកាន់កាប់យោធាយួននៅស្រុកខ្មែរ ដើម្បីប្រយោជន៍យួន មានសុពលភាពឡើងវិញ ព្រោះថា កិច្ចព្រមព្រៀងសន្តិភាព ថ្ងៃទី ២៣ តុលា ឆ្នាំ ១៩៩១ បានទុកវាជាមោឃៈ។

ដូច្នេះ ក្ដីសង្ឃឹមលើអ្វីដែលមានតម្លៃអវិជ្ជមានសំរាប់ប្រជាជាតិខ្មែរ វាជាក្ដីសង្ឃឹមឃាតករ ព្រោះវាជាការសម្លាប់ សន្ទុះលោតដែល សម រង្ស៊ី កំពុងធ្វើសព្វថ្ងៃនេះ ដែលជាសកម្មភាព អាចទុកជាការតស៊ូ ប្រឆាំងនឹងអំណាចផ្ដាច់ការ។ ដូច្នេះ គួរ សម រង្ស៊ី គាត់ផ្ដោត ស្មារតី នៃក្ដីសង្ឃឹម លើប្រជាពលរដ្ឋខ្មែរ វាប្រសើរជាង លើក គុណូបការៈមិនពិត របស់ សព ជា ស៊ីម យកមកធ្វើជាបំណើកនយោបាយប្រឆាំងនឹង ហ៊ុន សែន។ ជា ស៊ីម, ហេង សំរិន, ហ៊ុន សែន, ស ខេង, សាយ ឈុំ និង មន្ត្រីថ្នាក់ដឹកនាំ នៃគណបក្សប្រជាជន ជាមនុស្ស នៅក្នុងក្រុមគំនិតតែមួយ គឺក្រុមអ្នកបំផ្លាញកិច្ចព្រមព្រៀងសន្តិភាពថ្ងៃទី ២៣ តុលា ដើម្បីសំរួលឱ្យយួនកុម្មុយនិស្ត កៀរស្រុកខ្មែរ បញ្ចូលទៅក្នុងសហព័ន្ធតណ្ហូចិនរបស់យួន សំរាប់យកទឹកដីខ្មែរធ្វើជាទឹកដីរបស់ប្រជាជនយួន។ រឿងនេះឯង វាជាការពិតសំរាប់ប្រជាជនខ្មែរ ហើយក៏ជាការពិត សំរាប់ប្រជាជនយួនផងដែរ ព្រោះសព្វថ្ងៃនេះ ប្រជាជនយួនគេអាចចូលមករស់នៅក្នុងស្រុកខ្មែរបានដោយសេរី ព្រោះជាគោលការណ៍នយោបាយរបស់យួន នៅក្នុងស្មារតី : « ប្រជាជនយួន គ្មានដី មករស់នៅ លើដីគ្មានយួនរស់នៅ »។

## ក្តីសង្ឃឹមឃាតករ

ម្យ៉ាងមួយវិញទៀត មានខ្មែរមួយចំនួន កុំនាំគ្នានឹកស្មានថា ចិន ចូលស្រុកខ្មែរ ជាក្តីសង្ឃឹមថ្មីសំរាប់ខ្មែរ ព្រោះថាចិន គេចូលមកធ្វើជំនួញ សំរាប់រកចំណេញ មិនមែនមកការពារខ្មែរ សំរាប់ទប់ទល់នឹង អនុត្តរភាពយួននៅស្រុកខ្មែរនោះទេ។ រឿងជម្លោះ ចិន និង យួន លើ លក្ខន្តិកៈរបស់ខ្មែរសំរាប់ពួកគេ វាមានការសំរេចកំបាំងរួចស្រេចមកហើយ គឺថា ចិន គេទទួលស្គាល់ឥទ្ធិពលយួននៅស្រុកខ្មែរ តែយួន ត្រូវឱ្យចិន មានសិទ្ធមកធ្វើជំនួញនៅលើទឹកដីខ្មែរដែរ។

ត្រូវដឹងដែរថា តាំងតែចិន ទទួលស្គាល់ជាផ្លូវការអធិបតេយ្យភាពស្រុកយួននៅឆ្នាំ ១១៦៤ បន្ទាប់ពីមានទំនាស់យោធាដ៏យូរអង្វែង រវាងប្រទេសទាំងពីរមក ទំនាក់ទំនងរបស់ប្រទេសទាំងពីរ ក៏ចាប់មានស្ថេរភាពរីកចំរើនបន្តិចម្តងៗ។ ចិន វៀរមិនធ្វើអន្តរាគមន៍ លើ នយោបាយរបស់យួន រុករានចូលប្រទេសជិតខាង ដូចយ៉ាង នគរចាម ខ្មែរ និង លាវ ដរាបណាវាមិនគំរាមដល់ព្រំដែនចិន។ ជាការពិតណាស់ ជួនកាល វាមានការប៉ះទង្គិចអាវុធគ្នា រវាងឆ្នាំព្រំដែន រហូតបង្កើតជាសង្គ្រាមដូចយ៉ាងនៅឆ្នាំ ១៩៧៩, តែជាសង្គ្រាម នៅក្នុងក្រឡាដីតូចហើយនៅទីបញ្ចប់ តែងតែមានដំណោះស្រាយតាមសន្តិវិធី នៅក្នុងក្របខណ្ឌ នៃញាតិវប្បធម៌ ព្រោះថា ប្រទេសទាំងពីរ គេមាន វប្បធម៌, ប្រពៃណីរដ្ឋបាល និង គំនិតនយោបាយតែមួយ។ ពួកគេរមែងកោតសរសើរ និង គោរពគ្នាទៅវិញទៅមក។ ស្រុកចិនកុម្មុយនិស្ត ទុកស្រុកយួន ជាស្រុកកុម្មុយនិស្ត ដ៏ប្រសើរ

## ភ្លឺសង្ឃឹមឃាតករ

ហើយជា ប្រជាជាតិចាស់ទុំ មានសមត្ថភាពគ្រប់គ្រាន់ អាចការពារ អធិបតេយ្យភាពជាតិខ្លួន ពីការឈ្លានពាន ពីសំណាក់អធិរាជចិន, អាណានិគមបារាំងសែស និង ចក្រពត្រអាមេរិកាំង។ រីឯ យៀកណាម វិញ សំឡឹងមើលទៅប្រទេសចិន ដោយការព្រួយបារម្ភ និង ការគោរពផង។ ការព្រួយបារម្ភ ពីព្រោះ នគរខ្លួន មានព្រំដែនរួម ជាមួយប្រទេស ជាមហាអំណាចសេដ្ឋកិច្ចនៅក្នុងពិភពលោក និង មាន ចំនួនប្រជាជន ជាងមួយកោដិនាក់។ ការគោរព ព្រោះ ខ្លួនតែងតែទុកចិន ជាគំរូសំរាប់ខ្លួនហើយ ជាអ្នកការពារ ដោយគ្មានលក្ខណ ដល់ប្រជាជនយួន ក្នុងការតស៊ូ ដើម្បីឯករាជ្យជាតិ ប្រឆាំងនឹងការត្រួតត្រារបស់លោកខាងលិច។ ជានិច្ច ចិន និង យួន គេមានមូលហេតុរួម គឺការពារលទ្ធិកុម្មុយនិស្ត ដែលត្រូវបានគំរាមកំហែងពីជ័យជំនះនៃលទ្ធិប្រជាធិបតេយ្យនៅលើពិភពលោក។ ដូច្នេះ គេសន្មត់ថាប្រទេសទាំងពីរ ពួកគេ ត្រូវតែស្ថិតនៅជាមិត្តនឹងគ្នា ទោះបីមានទំនាស់នឹងគ្នា នៅក្នុងកិច្ចការបរទេស ដូចយ៉ាង ការងាករបស់យួន ទៅជិតនឹងសហរដ្ឋអាមេរិក។ តែបើគេតាមដាននយោបាយរបស់យួនបន្តិច គេឃើញថា ហាណូយ តាំងពីសង្គ្រាមលើកទី១ នៅឥណ្ឌូចិនមកម្លេះ ប្រទេសយួនខាងជើងតែងតែស្វែងរក កូនប្រយោល នៅក្នុងទំនាក់ទំនងខ្លួនជាមួយចិន ដែលជាសាមន្តប្រទេស និង ញាតិវប្បធម៌រួម។ នៅពេលសង្គ្រាមរំដោះ, ហាណូយ បានស្វែងរកការគាំទ្រពីសហភាពសូវៀត តែមិនដែលទុកចិន ជាសត្រូវនោះឡើយ ព្រោះពេល

នោះ ហាណូយ ត្រូវការពាំនឹងដ៏ធំមួយ ពីសំណាក់លោកកុម្មុយនិស្ត។ ជម្រើសនេះ វាគ្មានរំខានអ្វីដល់ចិនទោះឡើយ, ផ្ទុយទៅវិញ ចិនតែងតែលើក ទឹកចិត្តយួន ជាប្អូនរួមរប្បធម៌ ឲសេពគប់ ជាមួយនឹងប្រទេស ទាំងឡាយ ដែលមានប្រយោជន៏ដល់យួនកុម្មុនិស្ត។ តែនៅពេលសង្គ្រាម ផ្ទុះឡើងនៅស្រុកខ្មែរ នៅឆ្នាំ ១៩៧០ ក្រោយពីស្តេចសីហនុ ត្រូវគេទម្លាក់ពីអំណាច វាមានទំនាស់កើតឡើងរវាង ចិន និង យួន ក្នុងជម្រើសផ្តល់ជំនួយដល់ពួកខ្មែរក្រហម ដើម្បីច្បាំងប្រឆាំងនឹង សារធារណរដ្ឋខ្មែរ។ ចិនមានគោលបំណងចង់ឲការតស៊ូអាវុធ របស់ពួកខ្មែរក្រហមមានស្វ័យភាពពេញលេញ ចំពោះមុខ កងទ័ពរំដោះយួន តែហាណូយ វិញ មិនស្របនឹងការចង់បាន របស់ចិននោះឡើយព្រោះគេ ចង់បញ្ចូលកងទ័ពតស៊ូខ្មែរ នៅក្នុង យុទ្ធសាស្រ្តយួនតែមួយ ក្នុងសមរភូមិយោធានៅឥណ្ឌូចិន ដែលមានយួន ជាមេបញ្ជាការតែមួយ លើទ័ពតស៊ូ យួន ខ្មែរ និង លាវ។ បន្ទាប់ពីចុះហត្ថលេខា កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុង ប៉ារីស នៅថ្ងៃទី២៧ មករា ឆ្នាំ ១៩៧៣ យួនកុម្មុយនិស្ត អនុញ្ញាតអោយបក្សខ្មែរក្រហម ដឹកនាំនយោបាយតស៊ូយោធាដោយខ្លួនឯងតែយួននៅរក្សាកងទ័ពនៅស្រុកខ្មែរ ដើម្បីបន្តសង្គ្រាមប្រឆាំងនឹងយៀកណាមខាងត្បូង : ចិន យល់ស្របទាំងស្រុង។ ក្រោយពីពួកខ្មែរក្រហម មានជ័យជំនះ នៅឆ្នាំ ១៩៧៥ ចិនជាអ្នកមានអំណាចដាច់មុខនៅស្រុកខ្មែរ ដែលជាទីកន្លែងមួយ ដែលសេរីភាពគ្រប់បែបយ៉ាង ត្រូវលុបបំបាត់ចោល។ បក្សកុម្មុយនិស្ត

## ភ្លឹសឡ្យឹមឃាតករ

ខ្មែរចិនយានកម្ម មានអំណាចផ្ដាច់ការ អាចសម្លាប់បានប្រជាជនខ្មែរបាន។ ដូច្នេះ ចិន ជាអ្នកប្រៀនប្រដៅ ប៉ុល ពត ក្នុងរយៈពេលជាងបីឆ្នាំ ឱ្យនរៈជននេះ អនុវត្តនយោបាយប្រល័យពលរដ្ឋខ្មែរ ដើម្បីកសាងកម្ពុជាថ្មី។

ក្រោយពី យៀកណាមខាងជើង មានជ័យជំនះលើ យៀកណាមខាងត្បូង, ហាណូយ សម្រេចចិត្តដកទ័ពពីស្រុកខ្មែរ។ ប៉ុន្តែ ការដកទ័ពនោះ គឺនៅក្នុងផែនទី ដែលយួន ជាអ្នកព្រាយបន្ទាត់ព្រំដែន មិនមែនយកផែនទី ដែលអន្តរជាតិទទួលស្គាល់មកប្រើនោះឡើយ។ ទង្វើនេះ ដែលនាំបង្កើតជាជម្លោះព្រំដែន រវាងយៀកណាមបង្រួបបង្រួមតែមួយ និង កម្ពុជាប្រជាធិបតេយ្យ។ ហើយ ជម្លោះនេះ នាំបង្កជាសង្រ្គាម ដែល យួន ជាអ្នកមានជ័យជំនះ ហើយកងទ័ពយួន បានកាន់កាប់ស្រុកខ្មែរ អស់រយៈពេល១០ឆ្នាំ។ ទង្វើនេះ ធ្វើឲចិនមានការភ្ញាក់ផ្អើល នៅចំពោះមុខភាពមោះមុត និង ជោគជ័យឆាប់រហ័សរបស់យួន មកលើពួកខ្មែរក្រហម ដែលខ្លួនជាអ្នកការពារ។ ត្រូវដឹងថា នៅពេលនោះចិន គ្មានលទ្ធភាពអ្វីបន្តិចសោះឡើយ ដើម្បីការពារស្រុកខ្មែរ ដែលជានគរចុះទុនខ្សោយ ដោយសារអនុវត្ត នយោបាយប្រល័យពូជសាសន៍ខ្លួនឯង។ ត្រូវដឹងទៀតថា បើគ្មានសហគមអន្តរជាតិ ផ្តន្ទាទោស នៃការឈ្លានពានរបស់យោធាយួន មកលើស្រុកខ្មែរ វាច្បាស់ជា គ្មានការតស៊ូខ្មែរ មិនកុម្មុយនិស្តប្រឆាំងនឹងយោធាយួននៅតាមព្រំដែន ខ្មែរ-ថៃ នោះឡើយ ព្រោះចិន នៅតែបន្តជួយពួក ប៉ុល ពត ជានិច្ច ទោះបីដឹកថា

## ក្តីសង្ឃឹមឃាតករ

ពួកនេះជាឃាតករសម្លាប់ប្រជាជនជាតិខ្មែរ។ ដូច្នេះ ការមានក្តីសង្ឃឹមថ្មី ទៅលើចិន ក៏ជាក្តីសង្ឃឹមឃាតករផងដែរ។ ការពិតក្តីសង្ឃឹម ដែលប្រជាពលរដ្ឋខ្មែរ ត្រូវមាន គឺត្រូវពឹងផ្អែក លើកម្លាំងខ្លួនឯង ដោយភាពជឿជាក់ និង ការប្តេជ្ញាចិត្ត។ សមរង្ស៊ី និង គណបក្សសង្គ្រោះជាតិ ត្រូវទុក គណបក្សប្រជាជន ជាគូប្រជែងនយោបាយជាដាច់ខាត នៅក្នុងក្របខណ្ឌលទ្ធិប្រជាធិបតេយ្យ ដូច្នេះគោលដៅតែមួយគត់ គឺប្រយុទ្ធយកឈ្នះគណបក្សប្រជាជន តាមការបោះឆ្នោត ដើម្បីប្តូររបបដឹកនាំ៕